ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១៣៧/១០-អ៊ី សាំង**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១២ ខែមករា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន អ៊ី សាំង**

អាសយដ្ឋាន : តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ សង្កាត់ភ្លើងឆេះរទេះ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨៤២ ៧៦០ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក Wu Kuo An | Vice General Manager |
| ២- លោក ស៊ាវ គឹមឆាយ | ជំនួយការនាយក |
| ៣- កញ្ញា សុខ ចាន់ថា | រដ្ឋបាល |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ : - **សម្ព័ន្ធសហជីពកម្ពុជាអាស៊ី**

- **សហជីពកម្ពុជាអាស៊ីនៃក្រុមហ៊ុន អ៊ី សាំង**

អាសយដ្ឋាន : ភូមិថ្មី សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១០ ៩៤៣ ០២០ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក នួន ចន្ថា | ប្រធានសម្ព័ន្ធសហជីពកម្ពុជាអាស៊ី |
| ២- លោក នូ ជ័យរិទ្ធ | មន្ត្រីសម្ព័ន្ធសហជីពកម្ពុជាអាស៊ី |
| ៣- កញ្ញា ជរ សំបូរ | ប្រធានសហជីពកម្ពុជាអាស៊ី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករចំនួន ១០ នាក់ទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាការងារជាថ្មី ដោយហេតុថា ក្រុមហ៊ុននៅមានការងារធ្វើនៅឡើយ ព្រមទាំងមានធ្វើការបន្ថែមម៉ោងទៀតផង សម្រាប់វេនទី១ និងវេនទី២ ។

ចំពោះក្រុមហ៊ុនមិនឯកភាពបន្តកិច្ចសន្យាការងារជាថ្មីទៀតទេ ដោយមូលហេតុថា នៅពេលនេះ ក្រុមហ៊ុន កំពុងជួបនឹងការលំបាកផ្នែកសេដ្ឋកិច្ច ពុំមានការបញ្ជាទិញទំនិញពីអតិថិជន ដូច្នេះក្រុមហ៊ុន បានកាត់បន្ថយសង្វាក់ផលិតកម្មផ្នែកខ្លះដែលត្រូវកាត់បន្ថយកម្មករមួយចំនួន ក្នុងនោះ គឺអ្នកដែលដល់កិច្ចសន្យាមានថិរវេលាកំណត់នឹងបញ្ចប់នាថ្ងៃទី១៨-១៩-២២-២៤ ខែវិច្ឆិកា ឆ្នាំ២០១០ មានចំនួន ១០ នាក់ ( ក្រុមហ៊ុនបានជូនដំណឹងអំពីការមិនបន្តកិច្ចសន្យាការងាររួចរាល់ហើយ ) ។ ក្រុមហ៊ុននឹងទូទាត់ប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗតាមច្បាប់ស្តីពីការងារ ។

២- កម្មករទាំង ១០ នាក់ទាមទារឱ្យក្រុមហ៊ុនកុំមានការរើសអើងប្រឆាំងសហជីព ដោយមូលហេតុក្រុមហ៊ុនមិនបន្តកិច្ចសន្យាការងារឱ្យថ្នាក់ដឹកនាំសហជីព និងសមាជិកសហជីព ។

ចំពោះបញ្ហានេះ ក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនពុំមានការរើសអើងប្រឆាំងនឹងសហជីពម្តងណាឡើយ ក្រុមហ៊ុនខិតខំសហការ ដើម្បីបង្កើតកិច្ចសហការល្អជាមួយកម្មករនិយោជិតទាំងអស់ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ( អាណត្តិទី៤ ) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១៤១/១០ ភតសព ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០។

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ការិយាល័យតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ បានទទួលពាក្យបណ្តឹងសម្ព័ន្ធសហជីពកម្ពុជាអាស៊ី ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់កម្មករនិយោជិត ស្តីពីការទាមទារឱ្យក្រុមហ៊ុនអនុវត្តជាបន្ទាន់នូវលក្ខខណ្ឌការងារ ។

បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក មន្ត្រីការិយាល័យតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ បានធ្វើការដោះស្រាយវិវាទការងាររួមនេះ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ២ ចំណុច លើការទាមទារចំនួន ២ ចំណុច។ ចំណុចវិវាទដែលមិនសះជានឹងគ្នាចំនួន ២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ២ ចំណុចនេះ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ១៤:០០ នាទី រសៀល។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាទាំង ២ ចំណុចនេះបន្ថែមទៀត ហើយជាលទ្ធផលភាគីកម្មករនិយោជិត បានបញ្ចូលចំណុចវិវាទទី១ និងចំណុចវិវាទទី២ ជាចំណុចវិវាទតែមួយ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណា និងដោះស្រាយ លើចំណុចវិវាទនេះ ដោយផ្អែកលើ ភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លក្ខន្តិកៈក្រុមហ៊ុន អ៊ី សាំង លេខ ០៤២/០៩ ភកសព ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន អ៊ី សាំង ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៩ ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន អ៊ី សាំង ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ។

៤- កិច្ចសន្យាការងាររបស់ឈ្មោះ យ៉ង់ មករា ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ។

៥- កិច្ចសន្យាការងាររបស់ឈ្មោះ សួរ មុំ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ។

៦- កិច្ចសន្យាការងាររបស់ឈ្មោះ អ៊ុច សុវណ្ណារ៉ា ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ។

៧- កិច្ចសន្យាការងាររបស់ឈ្មោះ កង ស្រីពៅ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ។

៨- កិច្ចសន្យាការងាររបស់ឈ្មោះ ស៊ុន វណ្ណារិទ្ធ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ។

៩- កិច្ចសន្យាការងាររបស់ឈ្មោះ ថៃ តារ៉ា ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ ។

១០- កិច្ចសន្យាការងាររបស់ឈ្មោះ ឌឹម សៀងលី ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ ។

១១- កិច្ចសន្យាការងាររបស់ឈ្មោះ អ៊ឹម ម៉ាលីន ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ ។

១២- កិច្ចសន្យាការងាររបស់ឈ្មោះ ឃុត ស្រីនាង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១០ ។

១៣- កិច្ចសន្យាការងាររបស់ឈ្មោះ ជរ សំបូរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ ។

១៤- មតិរបស់ប្រធានគ្រប់គ្រងចំពោះកម្មករឈ្មោះ ថៃ តារ៉ា, ឌឹម សៀងលី, ជរ សំបូរ, អ៊ឹម ម៉ាលីន យ៉ង់ មករា, ឃុត ស្រីនាង, កង ស្រីពៅ, សួរ មុំ, អ៊ុច សុវណ្ណារ៉ា, ស៊ុន វណ្ណារិទ្ធ, ម៉ៅ សុជាត, ណុច ចន្ថន, ឃីន ស្រីមុំ, នួន សុភី, ហុង ស្រីដែន, នៅ អ៊ុត, សែត សារ៉ន, កយ ហន, ភាន រ៉ន, សៅ យ៉ា, ម៉ៅ សារ៉ែន, ស៊ុន សុមាលី, អ៊ិន សត់ ។

១៥- កិច្ចសន្យាការងាររបស់ឈ្មោះ នួន សុភី ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

១៦- កិច្ចសន្យាការងាររបស់ឈ្មោះ ឃីន ស្រីមុំ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

១៧- កិច្ចសន្យាការងាររបស់ឈ្មោះ ម៉ៅ សារ៉ែន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

១៨- កិច្ចសន្យាការងាររបស់ឈ្មោះ ណុច ចន្ថន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

១៩- កិច្ចសន្យាការងាររបស់ឈ្មោះ ស៊ុន សុម៉ាលី ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

២០- កិច្ចសន្យាការងាររបស់ឈ្មោះ ម៉ៅ សុជាតិ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

THE ARBITRATION COUNCIL

២១- កិច្ចសន្យាការងាររបស់ឈ្មោះ កយ ហាន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ។

២២- កិច្ចសន្យាការងាររបស់ឈ្មោះ ភាន រ៉ន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ។

២៣- កិច្ចសន្យាការងាររបស់ឈ្មោះ ហុង ស្រីដែន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ។

២៤- កិច្ចសន្យាការងាររបស់ឈ្មោះ នៅ អ៊ុត ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

២៥- កិច្ចសន្យាការងាររបស់ឈ្មោះ អ៊ិន សត់ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

២៦- កិច្ចសន្យាការងាររបស់ឈ្មោះ សែត សារ៉ន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

២៧- កិច្ចសន្យាការងាររបស់ឈ្មោះ សៅ យ៉ា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- សារណាសង្ខេប ស្តីពីវិវាទការងាររួមនៅក្រុមហ៊ុន អ៊ី សាំង ។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្ពុជាអាស៊ីនៃក្រុមហ៊ុន អ៊ី សាំង ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០

៣- លិខិតរបស់នាយកក្រុមហ៊ុន អ៊ី សាំង ជូនលោកស្រី ជរ សំបូរ ស្តពីការពុំបន្តកិច្ចសន្យាការងារ ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៤- លិខិតអញ្ជើញរបស់តំបន់រដ្ឋបាលសេដ្ឋកិច្ចពិសេសភ្នំពេញ ជូន សហជីព កម្មករនិយោជិត ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៥- កំណត់ហេតុស្តីពីការប្រជុំសាកសួរព័ត៌មានពីតំណាងកម្មករនិយោជិត ក្រុមហ៊ុន អ៊ី សាំង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន អ៊ី សាំង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៧- លិខិតរបស់សម្ព័ន្ធសហជីពកម្ពុជាអាស៊ី លេខ ០៦៥/១១/១០/CAC គោរពជូនលោកអនុប្រធានអធិការកិច្ចការងារ ប្រចាំតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ស្តីពីការជួយអន្តរាគមន៍ផ្សះផ្សាសំណុំរឿង ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៨- លិខិតពឹងពាក់របស់ថ្នាក់ដឹកនាំសហជីព និងសមាជិកសហជីពកម្ពុជាអាស៊ីក្រុមហ៊ុន អ៊ី សាំង គោរពជូនលោកប្រធានសម្ព័ន្ធសហជីពកម្ពុជាអាស៊ី ស្តីពីការជួយអន្តរាគមន៍ករណីក្រុមហ៊ុន អ៊ី សាំង មិនបន្តកិច្ចសន្យាការងារ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៩- កិច្ចសន្យាការងាររបស់ឈ្មោះ សួរ មុំ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ។

១០- កិច្ចសន្យាការងាររបស់ឈ្មោះ អ៊ុច សុវណ្ណារ៉ា ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ។

១១- កិច្ចសន្យាការងាររបស់ឈ្មោះ កង ស្រីពៅ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ។

១២- កិច្ចសន្យាការងាររបស់ឈ្មោះ ស៊ិន វណ្ណារិទ្ធ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ។

១៣- កិច្ចសន្យាការងាររបស់ឈ្មោះ ថៃ តារ៉ា ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ ។

THE ARBITRATION COUNCIL

១៤- កិច្ចសន្យាការងាររបស់ឈ្មោះ ឌឹម សៀងលី ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ ។

១៥- កិច្ចសន្យាការងាររបស់ឈ្មោះ អ៊ឹម ម៉ាលីន ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ ។

១៦- កិច្ចសន្យាការងាររបស់ឈ្មោះ ឃុត ស្រីនាង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១០ ។

២៨- កិច្ចសន្យាការងាររបស់ឈ្មោះ ជរ សំបូរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ ។

២៩- លិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារនិយោជិតមានថេរវេលាកំណត់ របស់ឈ្មោះ សួរ មុំ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣០- លិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារនិយោជិតមានថេរវេលាកំណត់ របស់ឈ្មោះ អ៊ុច សុវណ្ណារ៉ា ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣១- លិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារនិយោជិតមានថេរវេលាកំណត់ របស់ឈ្មោះ កង ស្រីពៅ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣២- លិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារនិយោជិតមានថេរវេលាកំណត់ របស់ឈ្មោះ ស៊ិន វណ្ណារិទ្ធ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣៣- លិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារនិយោជិតមានថេរវេលាកំណត់ របស់ឈ្មោះ ថៃ តារ៉ា ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣៤- លិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារនិយោជិតមានថេរវេលាកំណត់ របស់ឈ្មោះ ឌឹម សៀងលី ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣៥- លិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារនិយោជិតមានថេរវេលាកំណត់ របស់ឈ្មោះ អ៊ឹម ម៉ាលីន ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣៦- លិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារនិយោជិតមានថេរវេលាកំណត់ របស់ឈ្មោះ ឃុត ស្រីនាង ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣៧- លិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារនិយោជិតមានថេរវេលាកំណត់ របស់ឈ្មោះ យ៉ង មករា ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣៨- លិខិតរបស់សម្ព័ន្ធសហជីពកម្ពុជាអាស៊ី គោរពជូនលោកនាយកក្រុមហ៊ុន អ៊ី សាំង ស្តីពីការសុំបញ្ជាក់សមាជិកសហជីពកម្ពុជាអាស៊ី ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ ។

៣៩- លិខិតបំភ្លឺរបស់ សែត រ៉ន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៤០- កិច្ចសន្យាការងាររបស់ឈ្មោះ សែត រ៉ន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៤១- លិខិតបំភ្លឺរបស់ យ៉ន សុខនា ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៤២- កិច្ចសន្យាការងារ ( សាកល្បង ) របស់ឈ្មោះ យ៉ន សុខណា ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៤៣- លិខិតបំភ្លឺរបស់ ម៉ៃ គីមឡេង ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៤៤- កិច្ចសន្យាការងារ (សាកល្បង) របស់ឈ្មោះ ម៉ៃ គីមឡេង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ។

៤៥- កិច្ចសន្យាការងាររបស់ឈ្មោះ ម៉ៃ គីមឡេង ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០ ។

៤៦- លិខិតបំភ្លឺរបស់ អេង កូឡាប ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៤៧- កិច្ចសន្យាការងាររបស់ឈ្មោះ អេង កូឡាប ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០ ។

៤៨- លិខិតបំភ្លឺរបស់ ហួង សុភា ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៤៩- កិច្ចសន្យាការងាររបស់ឈ្មោះ ហួង សុភា ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៥០- លិខិតបំភ្លឺរបស់ ស៊ុំ សារុន ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៥១- កិច្ចសន្យាការងាររបស់ឈ្មោះ ស៊ុំ សារុន ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០ ។

៥២- លិខិតបំភ្លឺរបស់ នូ ម៉ាប់ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៥៣- កិច្ចសន្យាការងាររបស់ឈ្មោះ នូ ម៉ាប់ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០ ។

៥៤- កិច្ចសន្យាការងារ (សាកល្បង) របស់ឈ្មោះ នូ ម៉ាប់ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១០ ។

៥៥- លិខិតបំភ្លឺរបស់ ឃឿន លក្ខិណា ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៥៦- កិច្ចសន្យាការងាររបស់ឈ្មោះ ឃឿន លក្ខិណា ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០ ។

៥៧- លិខិតបំភ្លឺរបស់ ស៊ុន សុម៉ាលី នួន សុភី ឃឿន ស្រីមុំ នៅ អ៊ុត ម៉ៅ សារ៉ែន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៥៨- កិច្ចសន្យាការងាររបស់ឈ្មោះ ស៊ុន សុម៉ាលី ។

៥៩- កិច្ចសន្យាការងាររបស់ឈ្មោះ ម៉ៅ សារ៉ែន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦០- កិច្ចសន្យាការងាររបស់ឈ្មោះ នៅ អ៊ុត ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦១- កិច្ចសន្យាការងាររបស់ឈ្មោះ នួន សុភី ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦២- លិខិតបំភ្លឺរបស់ ឌិន សារឿន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦៣- លិខិតបំភ្លឺរបស់ កង ស្រីមុំ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦៤- លិខិតបំភ្លឺរបស់ ហេង ហាន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦៥- លិខិតបំភ្លឺរបស់ អ៊ុក ចំរើន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦៦- លិខិតបំភ្លឺរបស់ សៅ យ៉ា ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦៧- លិខិតបំភ្លឺរបស់ សេន ពេជ្រ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦៨- លិខិតបំភ្លឺរបស់ កយ ហន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦៩- កិច្ចសន្យាការងាររបស់ឈ្មោះ នាង ស្រីផុន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

១០- លិខិតរបស់សម្ព័ន្ធសហជីពកម្ពុជាអាស៊ីលេខ ០៨៧ CAC ២៥.១០.១០ គោរពជូនលោកនាយកក្រុមហ៊ុន អ៊ី សាំង ស្តីពីការបញ្ជាក់ចំនួនកម្មករនិយោជិតសរុប និងបញ្ជាក់សមាជិកសហជីពកម្ពុជាអាស៊ីសរុបនាពេលបច្ចុប្បន្ន ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អ៊ី សាំង លេខ ១៤១/១០ ភគសព ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន អ៊ី សាំង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៧៣៨ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៧៣៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន អ៊ី សាំង ចាប់ផ្តើមដំណើរការ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ គឺជាក្រុមហ៊ុនផលិតស្បាអាវពីជ័រប្លាស្ទិច។ បច្ចុប្បន្ននេះ ក្រុមហ៊ុនមានជួលកម្មករនិយោជិតសរុប ចំនួនប្រមាណ ១៩៩ នាក់។
- ក្រុមហ៊ុន អ៊ី សាំង មានបែងចែកម៉ោងការងារជា ៣ វេន គឺវេនទី១ ចាប់ផ្តើមធ្វើការងារពីម៉ោង ៦:០០ ព្រឹក ដល់ម៉ោង ២:៣០ នាទី ។ វេនទី២ ចាប់ផ្តើមធ្វើការងារពីម៉ោង ១:០០ ដល់ ម៉ោង ១០:០០ យប់ និងវេនទី៣ គឺចាប់ផ្តើមពីម៉ោង ១០:០០ យប់ ដល់ម៉ោង ៦:០០ ព្រឹក។ ជាទូទៅ បើមានការថែមម៉ោង គឺអាចត្រឹម ២ ម៉ោង ក្នុងមួយថ្ងៃ។
- សហជីពកម្ពុជាអាស៊ី គឺជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះ បានទទួលវិញ្ញាបនប័ត្រចុះបញ្ជិកា នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ ដែលមានកញ្ញា ជរ សំបូរ ជាប្រធានសហជីព លោកស្រី ស៊ុន សុម៉ាលី ជាអនុប្រធានសហជីព និងលោកស្រី នៅ រ៉ង ជាលេខាធិការសហជីព។ តាមរបាយការណ៍ដែលជម្រាបជូនទៅនិយោជក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ កម្មករនិយោជិតដែលជា

សមាជិកមានចំនួន ១១៥ នាក់។ ប៉ុន្តែ នៅក្នុងសវនាការ ភាគីនិយោជកបានលើកឡើងថា នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១០ និយោជកបានកាត់ភាគទានសហជីព ពីកម្មករនិយោជិតមានចំនួនតែ ៨៨ នាក់ប៉ុណ្ណោះ។

**ចំណុចវិវាទទី១ និងទី២ : ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាការងារជាថ្មី ជូនកម្មករនិយោជិតចំនួន ១០ នាក់ ដោយសារក្រុមហ៊ុនមានការរើសអើងសហជីព**

- ភាគីកម្មករនិយោជិតបានថា កម្មករនិយោជិតចំនួន ១០ នាក់ ដែលទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាការងារសារជាថ្មី។ តាមរយៈភស្តុតាងដែលផ្តល់ដោយភាគីសហជីព កម្មករនិយោជិតទាំងនោះមានដូចជា ឈ្មោះ ជរ សំបូរ. កង ស្រីពៅ. សួរ មុំ. ស៊ិន សុវណ្ណរិទ្ធ. អ៊ុច សុវណ្ណារ៉ា. ថៃ តារ៉ា. ឌឹម សៀងលី. យ៉ង់ មករា. អ៊ឹម ម៉ាលីន និង ឃុត ស្រីនាង។
- ភាគីកម្មករនិយោជិតអះអាងថា ក្រុមហ៊ុនមានការរើសអើងសហជីព ដោយហេតុថា ក្រុមហ៊ុនបន្តកិច្ចសន្យាការងារជូនកម្មករនិយោជិតសាកល្បង។ ប៉ុន្តែ កម្មករនិយោជិតពេញសិទ្ធិដែលជាសមាជិកសហជីពទាំង ១០ នាក់នេះ បែរជាក្រុមហ៊ុនពុំបន្តកិច្ចសន្យាការងារជូនពួកគាត់ទៅវិញ។ គោលបំណងដែលមិនបន្តនេះ គឺដើម្បីបន្ថយចំនួនសមាជិកសហជីព នៅពេលដែលដឹងថា សហជីពមានគំរោងស្នើសុំភាពជាតំណាងបំផុត នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០។
- ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនមិនបន្ត (បញ្ចប់) កិច្ចសន្យាដែលមានកំណត់ថិរវេលា ៣ ខែ ឬ ៦ ខែ សារជាថ្មី ទៅកម្មករនិយោជិតចំនួន ១០ នាក់ ពីព្រោះកិច្ចសន្យាការងារ របស់ពួកគាត់ដល់កាលកំណត់ ហើយនិយោជកបានជូនដំណឹងត្រឹមត្រូវ គឺក្រុមហ៊ុនពុំមានការរើសអើងសហជីពទេ។ បើក្រុមហ៊ុនមានរើសអើងសហជីពមែន ក្រុមហ៊ុនច្បាស់ជាបញ្ចប់កិច្ចសន្យារបស់កម្មករនិយោជិតដែលជាសមាជិកសហជីពទាំងអស់ ហើយមិនមែនបញ្ចប់កិច្ចសន្យាការងារតែចំនួន ១០ នាក់ទេ។ ភាគីនិយោជកអះអាងថា មូលហេតុដែលនិយោជក មិនបន្តកិច្ចសន្យាការងារជូននេះ គឺដោយសារចំនួនការងារមានការធ្លាក់ចុះខ្លាំង ជាពិសេសក្នុងរយៈពេល ២ ខែ នេះ កម្មករនិយោជិតពុំសូវមានការងារធ្វើទេ កម្មករនិយោជិតខ្លះទំនេរ ហើយអង្គុយលេង និងកម្មករនិយោជិតខ្លះ ក្រុមហ៊ុនឱ្យជូតជញ្ជាំង ជូតម៉ាស៊ីន ជូតកញ្ចក់ជាដើម រហូតដល់ធ្វើការបន្ថែមម៉ោង ជូតសំអាតនេះ ២ ម៉ោងផងដែរ។ ដោយឡែក ចំពោះការបន្ថែមម៉ោងតាមផ្ទៃកវិញ មានតិចតួចទេ គឺមានការងារបន្ថែមម៉ោង តែក្នុងករណីដែលអ្នកបញ្ជាទិញបានបង្ខំឱ្យពន្លឿនចំនួនផលិតផលតែប៉ុណ្ណោះ ពីព្រោះក្រុមហ៊ុន អ៊ី ស៊ាំង គឺជាក្រុមហ៊ុនទទួលទំនិញបន្តពីក្រុមហ៊ុន ក្នុងស្រុកដទៃមក ធ្វើតែប៉ុណ្ណោះ។

- ភាគីនិយោជកបានលើកឡើងថា ក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតកន្លងមក មាន ដូចខាងក្រោមៈ
    - នៅក្នុងខែកញ្ញា ឆ្នាំ២០១០ និយោជកបានបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិត ចំនួន ១០ នាក់ ហើយមានកម្មករនិយោជិតមួយចំនួនបានលាឈប់។
    - នៅក្នុងខែតុលា និយោជកបានបញ្ចប់កិច្ចសន្យាការងារប្រហែល ១០ នាក់ ទៀត។
    - នៅក្នុងខែវិច្ឆិកា និងខែធ្នូ និយោជកបានបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១០ នាក់ ដែលបានធ្វើការទាមទារនេះ ហើយក៏មានកម្មករនិយោជិតដែលលាឈប់មានចំនួន ១៥ នាក់ ផង ដែរ។ និយោជកពុំមានជ្រើសរើសកម្មករនិយោជិតថ្មីទេ។ ប៉ុន្តែ នៅក្នុងខែវិច្ឆិកា និងខែធ្នូនេះ និយោជកបានបន្តកិច្ចសន្យាជូនកម្មករនិយោជិត ចំនួន ១៣ នាក់ដែរ។ ភាគីកម្មករនិយោជិត ពុំបាន ជំទាស់ទៅនឹងការលើកឡើងនេះទេ។
    - ក្រុមហ៊ុនបានផ្តល់ឈ្មោះកម្មករនិយោជិតទាំង ១៣ នាក់ ដែលក្រុមហ៊ុនបន្តកិច្ចសន្យាសារជាថ្មី ជូននេះ មកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០ ហើយក្នុងនោះ ក្រុមប្រឹក្សា អាជ្ញាកណ្តាលបានរកឃើញថា មានកម្មករនិយោជិតចំនួន ៨ នាក់ គឺឈ្មោះ ម៉ៅ សុជាតិ, នួន សុភី, ហុង ស្រីដែន, នៅ អ៊ុត, កយ ហន, ភាន រ៉ន, សៅ យ៉ា និង ម៉ៅ សារ៉ែន ដែលជា សមាជិកសហជីព។
- ភាគីកម្មករនិយោជិតបានលើកឡើងថា កញ្ញា ជរ សំបូរ ធ្លាប់មានកិច្ចសន្យាការងារសាកល្បងរយៈ ពេល ៣ ខែ ហើយបន្ទាប់មក និយោជកបានបន្តកិច្ចសន្យាដែលមានកំណត់ថិរវេលា ៦ ខែ បន្តទៀត។ ប៉ុន្តែ នៅពេលដែលសហជីពធ្វើលិខិតសូមបញ្ជាក់ពីសមាជិកភាពរបស់សហជីព ដើម្បីសុំភាពតំណាង បំផុត និយោជក ពុំបានបន្តកិច្ចសន្យាការងារជូនគាត់តែម្តង។ ភាគីកម្មករនិយោជិតអះអាងថា កញ្ញា ជរ សំបូរ បានធ្វើសកម្មភាពសហជីពជាច្រើន ហើយគាត់តែងតែធ្លាប់បានចូលរួមដោះស្រាយជូនដល់ កម្មករនិយោជិត ដូចជា គាត់បានស្នើសុំឱ្យមានស្រោមដៃ កាសបិទត្រចៀក នៅពេលកំពុងធ្វើការងារ ជាដើម។ ប៉ុន្តែ ផ្ទុយទៅវិញ ចំពោះអនុប្រធានសហជីព ក្រុមហ៊ុនមិនបានបញ្ចប់កិច្ចសន្យានោះទេ គឺ ដោយសារគាត់ពុំសូវជួយការងារសហជីព ហើយមិនមែនជាមនុស្សដែលបង្ករបញ្ហាស្មុគស្មាញ ដល់ ក្រុមហ៊ុន។
- ភាគីនិយោជកបានបញ្ជាក់ថា មូលហេតុដែលនិយោជកមិនបន្តកិច្ចសន្យាការងារសារជាថ្មី ជូនកញ្ញា ជរ សំបូរ ពីព្រោះ កិច្ចសន្យារបស់គាត់ដល់កាលកំណត់ ហើយគាត់ធ្លាប់ទទួលការព្រមានដោយ ផ្ទាល់មាត់ និងប្រធានផ្នែក បានវាយតម្លៃថា ការងាររបស់គាត់ពុំសូវល្អ។

ARBITRATION COUNCIL

- ភាគីនិយោជកក៏បានផ្តល់ឯកសារ ភស្តុតាង បន្ថែម មកក្រុមប្រឹក្សាអាជ្ញាកណ្តាលនូវលិខិតដែលជារបស់ប្រធានគ្រប់គ្រងផ្នែកស្មាអារ ដែលធ្វើការវាយតំលៃលើកម្មករនិយោជិតថា សកម្មភាពការងារមិនល្អ។ លិខិតនេះ ធ្វើនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០។ ក្នុងចំណោមភស្តុតាងទាក់ទងនឹងលិខិតនោះក៏មានឈ្មោះកម្មករនិយោជិក ចំនួន ១០ នាក់ ដែលនិយោជកមិនបន្តកិច្ចសន្យាការងារនោះដែរ។ លិខិតទាក់ទងនឹងការវាយតំលៃនោះ មានឈ្មោះ កម្មករនិយោជិត ជរ សំបូរ ដែលប្រធានផ្នែកបានបញ្ជាក់ថា "*សកម្មភាពការងារមិនល្អ* "ដោយមានយោបល់បន្ថែមថា "*មិនបន្តកិច្ចសន្យា*" ។ *ក្រៅពីកម្មករនិយោជិត ជរ សំបូរ ក៏មានកម្មករនិយោជិត ខ្លះដូចជា កម្មករនិយោជិតឈ្មោះ ម៉ៅ សារ៉ែន* ប្រធានផ្នែកបានបញ្ជាក់ថា "*ការងារនិងអត្តចរិតល្អ* "ដោយមានយោបល់បន្ថែមថា "*បន្តកិច្ចសន្យា*" ។
- ក្នុងករណីនេះ កញ្ញា ជរ សំបូរ ក៏បានលើកឡើងថា គាត់ធ្លាប់មានទំនាស់ពាក្យសំដីជាមួយប្រធានផ្នែក ប្រាកដមែន ហើយពេលខ្លះគាត់ចេញតវ៉ាជូនកម្មករនិយោជិត ដែលធ្វើឱ្យមានបញ្ហាជាមួយប្រធានផ្នែក។
- ភាគីកម្មករនិយោជិតបានផ្តល់ភស្តុតាងបន្ថែមនូវលិខិតបំភ្លឺពីកម្មករនិយោជិត ចំនួន ២០ នាក់ ដែលបានបំភ្លឺថា បច្ចុប្បន្ននេះ ការងារនៅផ្នែកស្មាអារនៅវេនទី១ នៅមានការងារធ្វើដដែល ហើយមានការងារបន្ថែមម៉ោងទៀតផង។ ក្នុងចំណោមកម្មករនិយោជិត ២០ នាក់នោះ មានឈ្មោះ ឌិន សាវឿន អត្តលេខ ០១២២ បានបញ្ជាក់ថា " *ក្រុមហ៊ុនអ៊ីសាំងមានការងារផ្នែកស្មាអារ មានការងារធ្វើធម្មតាដូចខែមុនៗ រហូតមកដល់ឥឡូវ។..*"

## ហេតុផលនៃសេចក្តីសម្រេច:

**ចំណុចវិវាទទី១ និងទី២: *ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាការងារជាថ្មី ជូនកម្មករនិយោជិត ចំនួន ១០ នាក់ ដោយសារក្រុមហ៊ុនមានការរើសអើងសហជីព***

កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាការងារជាថ្មីជូនកម្មករនិយោជិតចំនួន ១០ នាក់ ដោយហេតុថា ក្រុមហ៊ុនមានការរើសអើងសហជីព ហើយក្រុមហ៊ុននៅមានការងារឱ្យកម្មករនិយោជិតធ្វើ ព្រមទាំងមានការងារបន្ថែមម៉ោងទៀតផង។ ភាគីនិយោជកលើកឡើងថា ក្រុមហ៊ុនមិនបន្ត កិច្ចសន្យាការងារថ្មីដល់កម្មករនិយោជិតចំនួន ១០ នាក់នោះទេ ពីព្រោះកិច្ចសន្យាការងាររបស់ពួកគាត់ដល់កាលកំណត់ ហើយក្រុមហ៊ុនមានការងារធ្លាក់ចុះខ្លាំង ដោយមិនពាក់ព័ន្ធនឹងការរើសអើងសហជីពទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាករណីនេះ ដូចតទៅ:

មាត្រា៧៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារចែងថា "*កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ត្រូវផុតរលត់តាមធម្មតានៅពេលដល់កាលកំណត់ ។ .......*"

នៅក្នុងសំណុំរឿងលេខ ១០០/០៧-ហ្វូយៀ ខេមបូឌា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា "*ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវផុតរលត់ជាស្វ័យប្រវត្តិនៅពេលដល់កាលកំណត់ ។ មានន័យថា កាតព្វកិច្ចរបស់ភាគីនិយោជក និងកម្មករនិយោជិត ត្រូវបានផុតរលត់ ។ ដូច្នេះ មិនមែនភាគីណាមួយអាចបង្ខំភាគីមួយទៀតឱ្យបន្តកិច្ចសន្យាទេ ប្រសិនបើគ្មានការព្រមព្រៀង ។*" (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១០០/០៧-ហ្វូយៀ ខេមបូឌា ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២*) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របទៅនឹងការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ គឺការផុតរលត់នៃកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលាធ្វើឱ្យទំនាក់ទំនងការងាររវាងកម្មករនិយោជិត និងនិយោជក ត្រូវផុតរលត់ជាស្វ័យប្រវត្តិ ហើយការសម្រេចចិត្តបន្តកិច្ចសន្យាសារជាថ្មីទៀត ឬមិនបន្តនោះ ជាសិទ្ធិរបស់ភាគីនៃកិច្ចសន្យា ព្រោះកិច្ចសន្យា គឺជាការព្រមព្រៀងរវាងភាគី ដែលមិនមានភាគីណាមួយអាចបង្ខំភាគីមួយទៀតឱ្យបន្តកិច្ចសន្យាទេ ប្រសិនបើគ្មានការព្រមព្រៀង ។

នៅក្នុងសំណុំរឿងនេះ កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ១០ នាក់ ដល់កាលកំណត់ ។ ភាគីនិយោជកបានធ្វើការជូនដំណឹងអំពីការមិនបន្តកិច្ចសន្យាការងាររបស់ពួកគាត់ ។ ហេតុនេះ ទំនាក់ទំនង និងកាតព្វកិច្ចការងាររវាងនិយោជក និងកម្មករនិយោជិត ត្រូវបានបញ្ចប់រួចរាល់ហើយ នៅពេលកិច្ចសន្យាការងាររបស់ពួកគាត់ដល់កាលកំណត់ ។ ប៉ុន្តែ នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតបានលើកឡើងថា មូលហេតុដែលនិយោជកពុំបន្តកិច្ចសន្យាជូនកម្មករនិយោជិតទាំង ១០ នាក់ ដោយសារតែមានការរើសអើងសហជីព ។

យោងតាមមាត្រា ១២ នៃច្បាប់ស្តីពីការងារបានចែងថា " ..... *គ្មាននិយោជកណាម្នាក់អាចយកបញ្ហាការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬ ការធ្វើសកម្មភាពក្នុងសហជីព ដើម្បីសម្រេចអំពី ....... ការជួល ...... ការផ្តាច់កិច្ចសន្យាការងារ .....* " ។

មាត្រា ២៧៩ នៃច្បាប់ស្តីពីការងារចែងថា " *ត្រូវហាមឃាត់ចំពោះនិយោជកគ្រប់រូបមិនអោយយកការចូលរួមជាសមាជិករបស់សហជីព ឬ ការចូលរួមក្នុងសកម្មភាពរបស់សហជីពនៃកម្មករនិយោជិត ដើម្បីធ្វើការសម្រេចក្នុងការជ្រើសរើសឱ្យចូលធ្វើការងារ ..... និងការបណ្តេញចេញ ....* " ។

សេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ *១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលនៃចំណុចវិវាទទី២* ដែលបានពោលថា "*...ទាំងការសម្រេចទាក់ទងទៅនឹងការមិនបន្តកិច្ចសន្យាមានថិរវេលាមិនកំណត់ និងទាំងការសម្រេចទាក់ទងទៅនឹងការបញ្ឈប់កម្មករ ដែលមានកិច្ចសន្យាគ្មានថិរវេលាកំណត់ គួរត្រូវបានគេពិចារណាថា ជាប្រភេទនៃការ*

*សម្រេច បញ្ចប់ដែលនិយោជកមិនអាចសម្រេច ដោយសារមូលហេតុជាសមាជិកសហជីព ឬ ការចូលរួមក្នុងសកម្មភាពសហជីពឡើយ*"។

តាមមាត្រា ១២ និង ២៧៩ នៃច្បាប់ស្តីពីការងារ និងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ស្របនឹងការបកស្រាយនេះដែរថា ប្រសិនបើការមិនបន្តកិច្ចសន្យាមានដែលកំណត់ថិរវេលា ដោយផ្អែកលើសកម្មភាពសហជីពរបស់កម្មករនិយោជិតនោះ ការសម្រេចមិនបន្តនោះ ជាការសម្រេចដែលផ្ទុយទៅនឹងច្បាប់ស្តីពីការងារ និងយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការបកស្រាយយ៉ាងស៊ីសង្វាក់គ្នាថា " *ជាទូទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថា ភាគីដែលធ្វើការចោទប្រកាន់មានបន្ទុកភស្តុតាងក្នុងការបង្ហាញមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីគាំទ្រការចោទប្រកាន់ទាំងនេះ។* " *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១១២/០៦-វីរីច ហេតុផលនៃចំណុចវិវាទទី១, លេខ ០១/០៧-ស៊ុខព្រីម, លេខ ១២៣/០៧-អ៊ី ហ្គាមេន ហេតុផលនៃចំណុចវិវាទទី១)* ។

ជាទូទៅ ទាក់ទងនឹងភស្តុតាងនៃការរើសអើងសហជីព ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើការឆ្លើយបំភ្លឺនៅក្នុងសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាងដែលពាក់ពន្ធ័ទៅនឹងសំណុំរឿង ដើម្បីកំណត់ថា មានការរើសអើងសហជីពកើតមានឡើងដែរឬទេ។ *(សូមមើលសេចក្តីបង្គាប់ លេខ ១៧/០៧-ឆាមថ៊ិចថាយ ហេតុផលនៃចំណុចវិវាទទី១ និងលេខ ១៤១/០៨- ប៊្លូមថេម ហេតុផលនៃចំណុចវិវាទទី៤)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ គឺភាគីកម្មករនិយោជិតមានបន្ទុកផ្តល់ភស្តុតាង ក្នុងការចោទប្រកាន់ថា និយោជករើសអើងសហជីព។

នៅក្នុងករណីនេះ តាមរយៈអង្គហេតុខាងលើ ភាគីកម្មករនិយោជិតបានបង្ហាញថា ការមិនបន្តកិច្ចសន្យាការងារជូនកម្មករនិយោជិតទាំង ១០ នាក់នេះ គឺដើម្បីបន្ថយចំនួនសមាជិកសហជីព នៅពេលដែលសហជីពមានគំរោងស្នើសុំភាពជាតំណាងបំផុតទៅក្រុមហ៊ុន នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពបានធ្វើលិខិតស្នើសុំបញ្ជាក់សមាជិកភាពទៅនិយោជកពិតប្រាកដមែន។ ប៉ុន្តែ លិខិតស្នើសុំតែមួយនេះ មិនអាចរកឃើញ និងសន្និដ្ឋានបានថា និយោជកមិនមានការរើសអើងសហជីពទេ ពីព្រោះ ការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ១០នាក់នេះ ពុំអាចកាត់បន្ថយចំនួនសមាជិកសហជីពដែលមានបំណងសុំបញ្ជាក់ពីភាពមានតំណាងបំផុតនោះទេ ។ មានន័យថា និយោជកត្រូវបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតច្រើនជាងនេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាបន្ថែមទៀតទៅលើការឆ្លើយបំភ្លឺរបស់ភាគី នៅក្នុងសវនាការ ។

នៅក្នុងសវនាការ ភាគីក្រុមហ៊ុនបានអះអាងថា មូលហេតុដែលក្រុមហ៊ុនមិនបន្តកិច្ចសន្យាការងារកម្មករនិយោជិតទាំង ១០ នាក់នេះ គឺ ដោយសារចំនួនការងារមានការថយចុះខ្លាំង ជាពិសេសក្នុងរយៈពេល ២ ខែនេះ កម្មករនិយោជិតពុំមានការងារធ្វើ កម្មករខ្លះទំនេរ ហើយអង្គុយលេង និងកម្មករខ្លះទៀត ក្រុមហ៊ុនឱ្យជូនជញ្ជាំង ជូនម៉ាស៊ីន និងជូនកញ្ចក់ជាដើម ។ ករណីនេះ កម្មករនិយោជិតមិនបានជំទាស់ទៅនឹងការលើកឡើងរបស់ក្រុមហ៊ុននេះទេ ។ ម្យ៉ាងទៀត ក្នុងកំឡុងពេលនិយោជកពុំមានការងារឱ្យធ្វើនេះ និយោជកបានបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតមួយចំនួនធំ ដូចជា នៅក្នុងខែកញ្ញា ឆ្នាំ២០១០ មានចំនួន ១០ នាក់ ក្នុងខែតុលា ឆ្នាំ២០១០ មានចំនួន ១០ នាក់ និងក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០១០ មានចំនួន ១០ នាក់ផងដែរ ។ ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលភស្តុតាងបន្ថែម នូវលិខិតបំភ្លឺរបស់កម្មករនិយោជិតចំនួន ២០ នាក់ដែលបានបំភ្លឺថា បច្ចុប្បន្ននេះការងារនៅផ្នែកស្ថាបត្យករនៅវេនទី១ នៅមានការងារធ្វើដដែល ហើយមានការងារបន្ថែមម៉ោងទៀតផង។ ក្នុងចំណោមកម្មករនិយោជិតចំនួន ២០ នាក់នេះ មាបឈ្មោះ ឌិន សារឿន អត្តលេខ ០១២២ បានបញ្ជាក់ថា ក្រុមហ៊ុន អ៊ី សាំង មានការងារផ្នែកស្ថាបត្យករ មានការងារធ្វើធម្មតាដូចខែមុនៗ រហូតមកដល់តឡូវ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការឆ្លើយបំភ្លឺរបស់ភាគីកម្មករនិយោជិតក្នុងថ្ងៃសវនាការ និងការផ្តល់ភស្តុតាងបន្ថែមជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មិនមានលក្ខណៈស៊ីសង្វាក់គ្នាទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញ និងសន្និដ្ឋានបានថា និយោជកមានការរើសអើងសហជីពពាក់ព័ន្ធនឹងការមិនបន្តកិច្ចសន្យាការងារ ជូនកម្មករនិយោជិតទាំង ១០ នាក់នេះ ទេ ។

ទន្ទឹមនឹងនោះដែរ តាមរយៈភស្តុតាង ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួល ក្រុមហ៊ុនបានបន្តកិច្ចសន្យាការងារសារជាថ្មីជូនកម្មករនិយោជិតមានចំនួន ១៣ នាក់ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្នុងនោះមានកម្មករនិយោជិតដែលក្រុមហ៊ុនបន្តកិច្ចសន្យាការងារសាជាថ្មីជូននេះ មានចំនួន ៨ នាក់ ដែលជាសមាជិកសហជីពផងដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកពិតជាមានការវាយតំលៃលើការងាររបស់កម្មករនិយោជិត ដោយផ្អែកលើគុណភាពការងារ និងអត្តចរិតរបស់កម្មករនិយោជិតម្នាក់ៗ មុននឹងសម្រេចថា បន្ត ឬមិនបន្តកិច្ចសន្យាការងារសារជាថ្មីជូន។

ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែបដិសេធការទាមទាររបស់កម្មករនិយោជិត ក្នុងករណីគ្មានភស្តុតាងគ្រប់គ្រាន់។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៧៤/០៧-កូបល អាប៉ារ៉ែល ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២, លេខ ៩៤/០៧-ហ្វរធ្យូន ហ្គាមេន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៦ និង ៨ និងលេខ ១០៨/០៨-ហ៊ូ ហ្គោ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៤)* ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានបានថា ក្រុមហ៊ុនមិនបន្តកិច្ចសន្យាការងារដល់កម្មករនិយោជិតទាំង ១០ នាក់ខាងលើ ពុំមានការទាក់ទងនឹងការរើសអើងសហជីពទេ ហើយតាមការបកស្រាយខាងលើ និយោជកមានសិទ្ធិក្នុងការសម្រេចមិនបន្តកិច្ចសន្យាការងារនៅពេលកិច្ចសន្យាការងារនោះ ដល់ចិរវេលាកំណត់។

ដូច្នេះ ជាសរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកបន្តកិច្ចសន្យាការងារជូនកម្មករនិយោជិតទាំង ១០ នាក់ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ :

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ និងទី២ :** បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកបន្តកិច្ចសន្យាការងារ ជូនកម្មករនិយោជិតទាំង ១០ នាក់។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **អ៊ុំ សុទ្ធី**

ហត្ថលេខា: ----------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **លឹម សុវណ្ណា**

ហត្ថលេខា: ----------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ----------------------------------

THE ARBITRATION COUNCIL